ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៤៧០៤/២៤ មស.សរណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ
## ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**យោង ៖** អនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល។

**គណៈកម្មការរៀបចំការប្រឡងប្រជែង** សូមជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា គណៈកម្មការនឹងរៀបចំឱ្យមានការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ប្រភេទក្របខណ្ឌ **"ក"** ចំនួន **២៥៧នាក់** ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធស្តីពីការបែងចែកមុខតំណែងជ្រើសរើសមន្ត្រីរាជការ(ឧបសម្ព័ន្ធទី១ និងទី២) និងលក្ខខណ្ឌដូចខាងក្រោម៖

### ក.លក្ខខណ្ឌជ្រើសរើស

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

២. បេក្ខជនត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ

៣.បេក្ខជនត្រូវមានអាយុយ៉ាងតិច **១៨ឆ្នាំ** និងអាយុយ៉ាងច្រើនបំផុត គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ តាមលក្ខខណ្ឌខាងក្រោម៖

- បេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនមានសញ្ញាបត្របណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុច្រើនបំផុត **៤០ឆ្នាំ**
- បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុច្រើនបំផុត **៣៥ឆ្នាំ**

៤. បេក្ខជនត្រូវជ្រើសរើសមុខតំណែងបម្រើការងារនៅតាមអង្គភាពចំណុះអគ្គនាយកដ្ឋានពន្ធដារ ដែលមានតម្រូវការជ្រើសរើស ដូចមានក្នុងតារាងឧបសម្ព័ន្ធស្តីពីការបែងចែកមុខតំណែងជ្រើសរើសមន្ត្រីរាជការ(ឧបសម្ព័ន្ធទី១ និងទី២) ឱ្យចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនភ្ជាប់ជាមួយសេចក្តីជូនដំណឹងនេះ

៥. បេក្ខជនដែលមិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ

៦. ការលើកទឹកចិត្ត និងការផ្តល់អាទិភាព៖

- ជនមានពិការភាពដែលមានគុណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងដែលបានដាក់ពាក្យ
- ស្ត្រី
- ជនជាតិដើមភាគតិច
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ
- បេក្ខជនមានអាយុច្រើនជាងគេ។



ផ្លូវវត្តអង្គតាមិញ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្ពុជា
St. Watangtaminh, Sangkat Chomchoa, Khan Posenchey, Phnom Penh, CAMBODIA
ទូរស័ព្ទ : (+៨៥៥) ២៣ ៨៦៦ ៥០១
Phone : (+855) 23 866 501
www.mcs.gov.kh

**ខ.កាលបរិច្ឆេទចុះឈ្មោះប្រឡងប្រជែង និងការដាក់ពាក្យ**

១. កាលបរិច្ឆេទចុះឈ្មោះប្រឡងប្រជែង៖ ចាប់ពីថ្ងៃទី**១៨** ខែវិច្ឆិកា ឆ្នាំ**២០២៤** រហូតដល់ ថ្ងៃទី**១៧** ខែធ្នូ ឆ្នាំ**២០២៤** វេលាម៉ោង **១៧:០០**នាទី ជាកំហិត

២. ការដាក់ពាក្យប្រឡងប្រជែងតាមរយៈប្រព័ន្ធអនឡាញ៖

- បេក្ខជនត្រូវស្កេន QR Code ខាងក្រោម ឬចូលទៅកាន់គេហទំព័រ https://go.gov.kh/era/mcstax ដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡងប្រជែង និងស្កេនបញ្ចូលឯកសារតម្រូវក្នុងការដាក់ពាក្យ
- បេក្ខជនត្រូវប្រើប្រាស់**លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** សម្រាប់ការចុះឈ្មោះតាមប្រព័ន្ធអនឡាញ។ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បេក្ខជនត្រូវធ្វើការទំនាក់ទំនងជាមួយមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដើម្បីជួយសម្រួលការចុះឈ្មោះ

៣. ឯកសារតម្រូវ ត្រូវស្កេនពីឯកសារច្បាប់ដើម ឬពីឯកសារមានបញ្ជាក់ផ្លូវការ៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បេក្ខជនត្រូវធ្វើការទំនាក់ទំនងជាមួយមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដើម្បីជួយសម្របសម្រួលបំពេញបែបបទ
- សញ្ញាបត្រ ឬសញ្ញាបត្រសមមូល តាមលក្ខខណ្ឌខាងលើ

  **បញ្ជាក់៖**

  - ចំពោះសញ្ញាបត្រសិក្សាក្នុងស្រុក ជាភាសាបរទេសត្រូវបញ្ជាក់ជាភាសាជាតិ នៅគ្រឹះស្ថានសិក្សារបស់ខ្លួន
  - ចំពោះសញ្ញាបត្រសិក្សានៅបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។
- រូបថតទំហំ ៤×៦ (ផ្ទៃខាងក្រោយពណ៌ស ឬផ្ទៃមេឃ) ថតថ្មី ៦ខែចុងក្រោយ
- **ចំពោះមន្ត្រីរាជការ** ត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងចេញដោយប្រធានស្ថាប័ន ឬអាជ្ញាធរដែលមានសិទ្ធិអនុញ្ញាតឱ្យផ្ទេរ(មានគំរូជូនភ្ជាប់)។

**សម្គាល់៖** នៅពេលប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវផ្តល់ឯកសារពាក់ព័ន្ធ ដើម្បីធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ ដូចខាងក្រោម៖

- សេចក្តីចម្លងវិញ្ញាបនបត្រ ឬសញ្ញាបត្រ (បញ្ជាក់ផ្លូវការ)
- សេចក្តីចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (បញ្ជាក់ផ្លូវការ)
- សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត
- លិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរ (សម្រាប់បេក្ខជនជាមន្ត្រីរាជការ)
- លិខិតបញ្ជាក់សុខភាព និងសារជាតុញៀន(សម្រាប់បេក្ខជនជានិស្សិត) 
- សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ (បញ្ជាក់ផ្លូវការ)
- រូបថតទំហំ ៤×៦ ចំនួន ០៤សន្លឹក។

**គ.លក្ខខណ្ឌតតិយុត្ត និងគោលការណ៍ផ្សេងៗ**

១. បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ មិនត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរកន្លែងបំពេញការងារដោយហេតុផលណាមួយឡើយ។ ការផ្លាស់ប្តូរកន្លែងបំពេញការងារ មានន័យថាសាមីជននោះបោះបង់ក្របខណ្ឌមន្ត្រីរាជការ។ ការផ្លាស់ប្តូរកន្លែងបំពេញការងារ អាចធ្វើទៅបានក្នុងករណីមានការសម្រេចពីរាជរដ្ឋាភិបាល ក្នុងការចាត់ចែងការប្រើប្រាស់មន្ត្រីរាជការផ្អែកលើការចាំបាច់

២. ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬលិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះ បានប្រឡងជាប់ជាស្ថាពរក៏ដោយ និងត្រូវប្រឈមចំពោះមុខច្បាប់ជាធរមាន

៣. បេក្ខសមណៈ (ជាបុព្វជិត ឬព្រះសង្ឃ) មានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និងសាសនា នៅពេលប្រឡងជាប់ជាស្ថាពរ តម្រូវឱ្យលាចាកសិក្ខាបទ និងមិនរក្សាមុខតំណែងឡើយ

៤. បេក្ខជនជាមន្ត្រីរាជការ ក្រោយពេលប្រឡងជាប់ជាស្ថាពរ ត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ និងត្រូវរៀបចំផ្ទេរបៀវត្សទៅកាន់អង្គភាពថ្មី។

## ឃ. វិញ្ញាសាប្រឡងប្រជែង

**១. វិញ្ញាសាសរសេរលើកទី១៖**

**១.១ មុខតំណែងក្នុងឧបសម្ព័ន្ធទី១**

| | | |
|---|---|---|
| - ភាសាអង់គ្លេស | រយៈពេល ១ម៉ោង | ៥០ពិន្ទុ |
| - សំណួរពហុចម្លើយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ | រយៈពេល ២ម៉ោង | ១០០ពិន្ទុ |

**សម្គាល់៖** ចំណេះដឹងទូទៅពាក់ព័ន្ធនឹង (១) មុខងារសាធារណៈ ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលសាធារណៈ វប្បធម៌ទូទៅ ពលរដ្ឋវិទ្យា ប្រវត្តិសាស្ត្រកម្ពុជា ភូមិសាស្ត្រកម្ពុជា អាស៊ាន និងសេដ្ឋកិច្ចកម្ពុជា ៣០% (២) ពាក់ព័ន្ធជំនាញពន្ធដារ និងឯកទេសនៃមុខតំណែង ៧០%

**១.២ មុខតំណែងក្នុងឧបសម្ព័ន្ធទី២**

| | | |
|---|---|---|
| - ភាសាអង់គ្លេស | រយៈពេល ១ម៉ោង | ៥០ពិន្ទុ |
| - សំណួរពហុចម្លើយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ | រយៈពេល ២ម៉ោង | ១០០ពិន្ទុ |

**សម្គាល់៖** ចំណេះដឹងទូទៅពាក់ព័ន្ធនឹង (១) មុខងារសាធារណៈ ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលសាធារណៈ វប្បធម៌ទូទៅ ពលរដ្ឋវិទ្យា ប្រវត្តិសាស្ត្រកម្ពុជា ភូមិសាស្ត្រកម្ពុជា អាស៊ាន និងសេដ្ឋកិច្ចកម្ពុជា ៣០% (២) ពាក់ព័ន្ធជំនាញពន្ធដារ និងគណនេយ្យ ៧០%

បញ្ជាក់៖ មានតែបេក្ខជនដែលប្រឡងប្រជែងជាប់វិញ្ញាសាសរសេរលើកទី១ប៉ុណ្ណោះ ទើបមានសិទ្ធិចូលរួមប្រឡងប្រជែងវិញ្ញាសាសរសេរលើកទី២។

**២. វិញ្ញាសាសរសេរលើកទី២៖**

**២.១ មុខតំណែងក្នុងឧបសម្ព័ន្ធទី១**

| | | |
|---|---|---|
| - ជំនាញពន្ធដារ | រយៈពេល ២ម៉ោង | ១០០ពិន្ទុ |
| - ជំនាញឯកទេស | រយៈពេល ២ម៉ោង | ១០០ពិន្ទុ |

**២.២ មុខតំណែងក្នុងឧបសម្ព័ន្ធទី២**

| | | |
|---|---|---|
| - ជំនាញពន្ធដារ | រយៈពេល ២ម៉ោង | ១០០ពិន្ទុ |
| - ជំនាញគណនេយ្យ | រយៈពេល ២ម៉ោង | ១០០ពិន្ទុ |

**បញ្ជាក់៖** មានតែបេក្ខជនដែលប្រឡងប្រជែងជាប់វិញ្ញាសាសរសេរលើកទី២ប៉ុណ្ណោះ ទើបមានសិទ្ធិចូលរួមធ្វើវិញ្ញាសាផ្ទាល់មាត់។

**៣.វិញ្ញាសាផ្ទាល់មាត់** (១០០ពិន្ទុ មេគុណ ២)៖ ធ្វើមូលវិចារលើបុគ្គលិកលក្ខណៈ ហេតុប្បទ្វេសរបស់បេក្ខជន ចំណេះដឹងពាក់ព័ន្ធនឹងជំនាញពន្ធដារ ជំនាញឯកទេសឬគណនេយ្យ (ផ្អែកលើមុខតំណែង) ចំណេះដឹងអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមុខងារសាធារណៈ ព្រមទាំងសមត្ថភាពជំនាញក្នុងការអនុវត្តការងារ (បទពិសោធការងារ) សម្រាប់រយៈពេល ១៥នាទី ទៅ ២០នាទី ក្នុងបេក្ខជន១នាក់។

**បញ្ជាក់៖ លទ្ធផលនៃការប្រឡងប្រជែង នឹងត្រូវកំណត់ផ្អែកលើពិន្ទុសរុបនៃវិញ្ញាសាទាំង៣។**

## ខ.សម័យប្រឡង និងមណ្ឌលប្រឡង

១. សម័យប្រឡង ៖ ជូនដំណឹងពេលក្រោយ

២. មណ្ឌលប្រឡង ៖ នៅរាជធានីភ្នំពេញ (ទីតាំងមណ្ឌលប្រឡង នឹងជូនដំណឹងពេលក្រោយ)

**បញ្ជាក់៖**

១. ចំពោះបេក្ខជនដែលបានចុះឈ្មោះរួចរាល់ សូមចូលទៅពិនិត្យមើលសារឆ្លើយតបក្នុងប្រព័ន្ធចុះឈ្មោះអនឡាញ តាមរយៈតំណភ្ជាប់ https://go.gov.kh/era/mcsreglogin ឬអ៊ីម៉ែលសាមីខ្លួន ដើម្បីបំពេញលក្ខខណ្ឌបន្តបន្ទាប់ពីក្រុមការងារបានពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានតម្រូវរួចរាល់។ បេក្ខជនត្រូវប្រើប្រាស់ព័ត៌មានផ្លូវការដែលផ្តល់ដោយប្រព័ន្ធចុះឈ្មោះ ដែលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈតែប៉ុណ្ណោះ

២. ចំពោះព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធចុះឈ្មោះតាមអនឡាញ សូមទំនាក់ទំនងតាមទូរស័ព្ទ និងប្រព័ន្ធTelegram ០១០ ៤៣៧៩២២, ០៩៨ ៥៥២៥៧៧, ០១០ ៤១៦៥៧៣, ០៦១ ២៦៨៩៩៩ រៀងរាល់ម៉ោងធ្វើការ

៣. គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់។

ថ្ងៃ ចន្ទ ៣ រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន**

**គណៈកម្មការរៀបចំការប្រឡងប្រជែង** [illegible]

**ហ៊ុន_ម៉ានី**

សូមស្កេនដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡងប្រជែង

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

គណៈកម្មការរៀបចំការប្រឡងប្រជែង

## តារាងឧបសម្ព័ន្ធ១

## ស្តីពី

## ការបែងចែកមុខតំណែងគាំទ្រសម្រាប់ជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារនៅនាយកដ្ឋានថ្នាក់កណ្តាលនៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ១ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- រដ្ឋបាលសាធារណៈ | ០២នាក់ | នាយកដ្ឋាន<br>រដ្ឋបាលនិងកិច្ចការទូទៅ |
| | មន្ត្រីផ្នែកទំនាក់ទំនងសាធារណៈ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- រដ្ឋបាលសាធារណៈ | ០១នាក់ | |
| | សរុប | | | ០៣នាក់ | |
| ២ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- រដ្ឋបាលសាធារណៈ | ០៤នាក់ | នាយកដ្ឋាន<br>ហិរញ្ញវត្ថុនិងបុគ្គលិក |
| | មន្ត្រីផ្នែកបុគ្គលិក | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- រដ្ឋបាលសាធារណៈ | ០២នាក់ | |
| | សរុប | | | ០៦នាក់ | |
| ៣ | មន្ត្រីផ្នែកនីតិកម្ម | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- ច្បាប់ | ០១នាក់ | នាយកដ្ឋាននីតិកម្ម<br>គោលនយោបាយសារពើពន្ធនិង<br>សហប្រតិបត្តិការពន្ធដារអន្តរជាតិ |
| | មន្ត្រីផ្នែកសហប្រតិបត្តិការពន្ធដារអន្តរជាតិ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- ច្បាប់ | ០១នាក់ | |
| | មន្ត្រីផ្នែកស្ថិតិ និងព្យាករណ៍ចំណូល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- សេដ្ឋកិច្ច | ០១នាក់ | |
| | សរុប | | | ០៣នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | ឯកទេស ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ៤ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- រដ្ឋបាលសាធារណៈ | ០១នាក់ | នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ |
| | មន្ត្រីផ្នែកពន្ធចលនទ្រព្យ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- ច្បាប់ | ០១នាក់ | |
| | មន្ត្រីផ្នែកពន្ធអចលនទ្រព្យ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- ច្បាប់ | ០២នាក់ | |
| | មន្ត្រីផ្នែកពន្ធប្រថាប់ត្រា | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- ច្បាប់ | ០២នាក់ | |
| | មន្ត្រីផ្នែកពន្ធចំណេញមូលធន | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- ច្បាប់ | ០៣នាក់ | |
| | សរុប | | | ០៩នាក់ | |
| **សរុបរួម** | | | | **២១នាក់** | |

ថ្ងៃ ចន្ទ ៣ រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង**

**ហ៊ុន ម៉ានី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

គណៈកម្មការរៀបចំការប្រឡងប្រជែង

# តារាងឧបសម្ព័ន្ធ២

## ស្ដីពី

## ការបែងចែកមុខតំណែងសម្រាប់ជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារនៅនាយកដ្ឋានថ្នាក់កណ្ដាល និង សាខាពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ១. នាយកដ្ឋានថ្នាក់កណ្ដាល (សរុបចំនួន ១១៨ នាក់) | | | | | |
| ១ | មន្ត្រីផ្នែកកិច្ចការទូទៅ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | នាយកដ្ឋាន រដ្ឋបាលនិងកិច្ចការទូទៅ |
| | មន្ត្រីផ្នែកពិគ្រោះយោបល់ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | មន្ត្រីផ្នែកចុះបញ្ជីពន្ធដារ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកសវនកម្មផ្ទៃក្នុង | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | សរុប | | | | ០៧នាក់ |
| ២ | មន្ត្រីផ្នែកហិរញ្ញវត្ថុនិងលទ្ធកម្ម | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៤នាក់ | នាយកដ្ឋាន ហិរញ្ញវត្ថុនិងបុគ្គលិក |
| | សរុប | | | | ០៤នាក់ |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ៣ | មន្ត្រីផ្នែកវិវាទ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធនិងសហប្រតិបត្តិការពន្ធដារអន្តរជាតិ |
| | សរុប | | | | ០២នាក់ |
| ៤ | មន្ត្រីផ្នែកស៊ើបអង្កេតបទល្មើសពន្ធដារ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៥នាក់ | នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ |
| | សរុប | | | | ០៥នាក់ |
| ៥ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ |
| | មន្ត្រីផ្នែកសវនកម្ម | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ៣០នាក់ | |
| | មន្ត្រីផ្នែកពាណិជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៤នាក់ | |
| | មន្ត្រីផ្នែកបង្វិលសងអាករលើតម្លៃបន្ថែម | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៨នាក់ | |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៤នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | មន្ត្រីផ្នែកបំណុលពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | | ៥០នាក់ |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៦នាក់ | |
| | មន្ត្រីផ្នែកសវនកម្ម | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ៣២នាក់ | |
| ៦ | មន្ត្រីផ្នែកជំរុញការប្រមូលបំណុលពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៤នាក់ | នាយកដ្ឋានសវនកម្មសហគ្រាស |
| | មន្ត្រីរៀបចំថ្លៃទុកជាមុន និងការផ្ទេរថ្លៃ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៨នាក់ | |
| | សរុប | | | | ៥០នាក់ |
| **២. សាខាពន្ធដារខណ្ឌ (សរុបចំនួន ៥០ នាក់)** | | | | | |
| | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| ៧ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌឫស្សីកែវ |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | សរុប | | | ០៥នាក់ | |
| | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| ៨ | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | សាខាពន្ធដារខណ្ឌដូនពេញ |
| | សរុប | | | ០៥នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ៩ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌ៧មករា |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | សរុប | | | ០៥នាក់ | |
| ១០ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌមានជ័យ |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៦នាក់ | |
| ១១ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌចំការមន |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៦នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ១២ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌទួលគោក |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | សរុប | | | ០៥នាក់ | |
| ១៣ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | សរុប | | | ០៥នាក់ | |
| ១៤ | មន្ត្រីផ្នែករដ្ឋបាល | ច្បាប់ /រដ្ឋបាលសាធារណៈ /គ្រប់គ្រង | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌសែនសុខ |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | |
| | សរុប | | | ០៨នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ<br>(កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា<br>ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ១៥ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខណ្ឌដង្កោ |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | មន្ត្រីផ្នែកចាត់ចែងលិខិតប្រកាស | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | |
| | សរុប | | | ០៥នាក់ | |
| **៣. សាខាពន្ធដារខេត្ត (សរុបចំនួន ៦៨ នាក់)** | | | | | |
| ១៦ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តបន្ទាយមានជ័យ |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៤នាក់ | |
| ១៧ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តបាត់ដំបង |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | |
| | សរុប | | | ០៥នាក់ | |
| ១៨ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកំពង់ចាម |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៤នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ១៩ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកំពង់ឆ្នាំង |
| | សរុប | | | ០២នាក់ | |
| ២០ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកំពង់ស្ពឺ |
| | សរុប | | | ០២នាក់ | |
| ២១ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកំពង់ធំ |
| | សរុប | | | ០២នាក់ | |
| ២២ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកំពត |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៤នាក់ | |
| ២៣ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកណ្ដាល |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | |
| | សរុប | | | ០៥នាក់ | |
| ២៤ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកោះកុង |
| | សរុប | | | ០២នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសាជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ២៥ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តក្រចេះ |
| | សរុប | | | ០២នាក់ | |
| ២៦ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | សាខាពន្ធដារខេត្តមណ្ឌលគីរី |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៣នាក់ | |
| ២៧ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តព្រះវិហារ |
| | សរុប | | | ០២នាក់ | |
| ២៨ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តព្រៃវែង |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | |
| | សរុប | | | ០៥នាក់ | |
| ២៩ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តពោធិ៍សាត់ |
| | សរុប | | | ០២នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ (កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ៣០ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០១នាក់ | សាខាពន្ធដារខេត្តរតនគីរី |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | |
| | សរុប | | | ០៣នាក់ | |
| ៣១ | មន្ត្រីផ្នែករដ្ឋបាល | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តសៀមរាប |
| | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០៣នាក់ | |
| | សរុប | | | ០៥នាក់ | |
| ៣២ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តព្រះសីហនុ |
| | សរុប | | | ០២នាក់ | |
| ៣៣ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តស្ទឹងត្រែង |
| | សរុប | | | ០២នាក់ | |
| ៣៤ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តស្វាយរៀង |
| | សរុប | | | ០២នាក់ | |
| ៣៥ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តតាកែវ |
| | សរុប | | | ០២នាក់ | |

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ<br>(កម្រិតបរិញ្ញាបត្រឡើង) | វិញ្ញាសា<br>ជំនាញ/ឯកទេស | ក្របខណ្ឌ ក | អង្គភាពបម្រើការងារ |
|---|---|---|---|---|---|
| ៣៦ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តឧត្តរមានជ័យ |
| | សរុប | | | ០២នាក់ | |
| ៣៧ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តកែប |
| | សរុប | | | ០២នាក់ | |
| ៣៨ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តប៉ៃលិន |
| | សរុប | | | ០២នាក់ | |
| ៣៩ | មន្ត្រីផ្នែកសេវាអ្នកជាប់ពន្ធ | គ្រប់គ្រងធុរកិច្ច/នីតិសាស្ត្រ/រដ្ឋបាលសាធារណៈ | - ពន្ធដារ<br>- គណនេយ្យ | ០២នាក់ | សាខាពន្ធដារខេត្តត្បូងឃ្មុំ |
| | សរុប | | | ០២នាក់ | |
| **សរុបរួម** | | | | **២៣៦នាក់** | |

ថ្ងៃ ច័ន្ទ ៣រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង**

**ហ៊ុន_ម៉ានី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង-ស្ថាប័ន/រាជធានី-ខេត្ត៖**.......................

**អង្គភាព៖**.......................................................

លេខ៖..............................................................

៤x៦

**លិខិតអនុញ្ញាត**

( សម្រាប់បេក្ខជនជាមន្ត្រីរាជការស៊ីវិល )

ត្រូវបានអនុញ្ញាតជូន លោក/លោកស្រី/កញ្ញា ឈ្មោះ៖.......................................................................

អក្សរឡាតាំង៖............................................ ភេទ៖............ សញ្ជាតិ៖........... ថ្ងៃខែឆ្នាំកំណើត៖...........................

អត្តលេខមន្ត្រីរាជការ៖............................................. លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖..........................................

ថ្ងៃខែឆ្នាំចូលបម្រើក្របខណ្ឌរដ្ឋ ៖.................................................................................

ថ្ងៃខែឆ្នាំតាំងស៊ប់ក្នុងក្របខណ្ឌ ៖.................................................................................

ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ចុងក្រោយ ៖.................................................................................

ថ្ងៃខែឆ្នាំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ចុងក្រោយ ៖.................................................................................

រយៈពេលបម្រើការងារ ៖.................................................................................

ជាមន្ត្រីកំពុងបម្រើការងារនៅនាយកដ្ឋាន/មន្ទីរ/អង្គភាព ៖.................................................................................

តួនាទីបច្ចុប្បន្ន ៖.................................................................................

ឱ្យចូលរួមប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងយល់ព្រមឱ្យផ្ទេរចេញនៅពេលបេក្ខភាពរូបនេះ បានប្រឡងប្រជែងជាប់ស្ថាពរ ដោយត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងជូនឡើយ។

ថ្ងៃ....................................... ខែ................ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅ.............................. ថ្ងៃទី......... ខែ.............. ឆ្នាំ២០២៤

**ប្រធានក្រសួង ស្ថាប័ន / រដ្ឋបាលថ្នាក់ក្រោមជាតិ**

១៧